# សំបុត្រព្រមានពីការជំនួសកាតប្រើហួសកម្រិត

កាលបរិច្ឆេទ ____________

______________________________
ឈ្មោះ(មេគ្រួសារ) អតិថិជន

______________________________
អសយដ្ឋាន

______________________________
ក្រុង, រដ្ឋ និងស៊ីបខូដ

______________________________
លេខក្រុមគ្រួសារ/លេខសំណុំរឿងខោនធី

គោរពជូន ____________

បញ្ជីកុំព្យូទ័ររបស់យើងបង្ហាញថាអ្នកបានប្រើប័ណ្ណបញ្ជូនប្រាក់តាមអេឡិចត្រូនិច [(Electronic Benefit Transfer) (EBT)] ថ្មីបួនដង ឬលើសក្នុងអំឡុងពេល 12 ខែកន្លងមក ។ ការនេះគឺបង្ហាញថាអ្នកប្រហែលមានបញ្ហាក្នុងការប្រើប័ណ្ណ EBT របស់អ្នក និង/ឬក៏ប្រហែលមកពីការប្រើប្រាស់ជំនួយ CalFresh របស់អ្នកមិនបានត្រឹមត្រូវ ។ អ្នកអាចប្រើប័ណ្ណ EBT តែមួយដូចគ្នារៀងរាល់ខែដរាបណាអ្នកនៅតែទទួលជំនួយចំណីអាហាររបស់អ្នក ។ បើសិនជាអ្នកមានបញ្ហាអ្វីមួយជាមួយនឹងប័ណ្ណ EBT របស់អ្នក, សូមទូរស័ព្ទដោយឥតបង់ថ្លៃមក បណ្តាញសេវាអតិថិជន EBT តាមលេខ 877-328-9677 ឬទាក់ទងមកអ្នកធ្វើការតាមខោនធីរបស់អ្នកដើម្បីស្វែងយល់ពីរបៀបប្រើប័ណ្ណរបស់អ្នក ។

វាជាការផ្ទុយពីច្បាប់ក្នុងការធ្វើ ឬប៉ុនប៉ងធ្វើប្រការអ្វីមួយដូចជាម ៖ ទិញ, លក់, លួច, ឬជួញដូរប័ណ្ណ EBT ឬជំនួយ CalFresh ។ រាល់ការលក់ដូររបស់ប័ណ្ណ EBT និងការប្តូរប័ណ្ណថ្មីគឺត្រូវបានត្រួតពិនិត្យដោយកុំព្យូទ័រ ។ យើងធ្វើនេះគឺចង់ឲ្យជាក់ច្បាស់ថាប័ណ្ណត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ ហើយដើម្បីការពារកុំឲ្យមានការប្រើប្រាស់បំពានលើកម្មវិធី CalFresh ។ ដោយសំអាងលើបញ្ជីកុំព្យូទ័រ, យើងអាចធ្វើការស៊ើបអង្កេតការប្រើប្រាស់មិនត្រឹមត្រូវណាមួយនៃប័ណ្ណ EBT របស់អ្នក ។ បើសិនជាអ្នកត្រូវបានគេរកឃើញថាជាអ្នកទទួលខុសត្រូវសំរាប់ការប្រើប្រាស់ប័ណ្ណ EBT របស់អ្នកមិនត្រឹមត្រូវ ជំនួយរបស់អ្នកប្រហែលជាត្រូវបញ្ឈប់ អ្នកប្រហែលជាត្រូវបង់សងប្រាក់ជំនួយវិញ ឬត្រូវផាកពិន័យ ឬបញ្ជូនទៅពន្ធនាគារ ឬគុក ។

ដើម្បីរក្សាជំនួយពីកម្មវិធី CalFresh របស់អ្នក គេសូមរំលឹកអ្នកថាប័ណ្ណនោះត្រូវប្រើសំរាប់តែទិញចំណីអាហារដែលអ្នក និងក្រុមគ្រួសារអ្នកបរិភោគតែប៉ុណ្ណោះ ឬគ្រាប់ពូជសំរាប់ដាំដំណាំជាចំណីអាហាររបស់ក្រុមគ្រួសារអ្នក ។ អ្នកអាចនៅរក្សាប្រើប័ណ្ណ EBT របស់អ្នកសំរាប់ក្នុងគោលបំណងទាំងឡាយខាងលើ ។ លិខិតនេះមិនកែប្រែជំនួយពីកម្មវិធី CalFresh របស់អ្នកទេ តែខោនធីនឹងទុកសំណៅចំឡងនៃលិខិតនេះមួយច្បាប់ក្នុងសំណុំរឿងរបស់អ្នក ។

អ្នកមិនចាំបាច់ធ្វើអ្វីទាំងអស់គ្រានេះ លើកលែងតែអ្នកប្រើប័ណ្ណជំនួយរបស់អ្នកឲ្យបានត្រឹមត្រូវ ។ បើអ្នកមានសំនួរអ្វីមួយអំពីលិខិតនេះ សូមទាក់ទងមក ______________________________.
(លេខទូរស័ព្ទទាក់ទងសំរាប់ខោនធី)